# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៩៨,៨៨0 ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារសិក្សា



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណេ) រដ្ឋាភិបាលជប៉ុននឹងផ្តល់ទឹកប្រាក់សរុបចំនួន៩៨,៨៨0ដុល្លាអាមេរិកដល់មន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញ សម្រាប់គម្រោងសាងសង់អគារសិក្សានៅអនុវិទ្យាល័យគោកបញ្ជាន់រាជធានីភ្នំពេញ។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តមម៉ាសាហ៊ីរ៉ូ គូរ៉ូគី ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក ជា ជាតិ ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញនៅស្ថានទូតជប៉ុន។

ដើម្បីបំពេញនូវកង្វះខាតផ្នែកបន្ទប់សិក្សា មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញនឹងអនុវត្តគម្រោងសាងសង់អគារសិក្សាបេតុងមួយខ្នងមាន៧បន្ទប់ រួមទាំងការបំពាក់បរិក្ខារសិក្សានៅអនុវិទ្យាល័យគោកបញ្ជាន់ស្ថិតក្នុងខណ្ឌពោធិ៍សែនជ័យរាជធានីភ្នំពេញ។ ជាផ្នែកមួយនៃគម្រោងនេះផងដែរ បន្ទប់ទឹកដែលមាន៨បន្ទប់នឹងត្រូវបានសាងសង់ផងដែរ។ យើងសង្ឃឹមថា សិស្សានុសិស្សជាង៦០០នាក់នឹងរីករាយជាមួយបរិស្ថាននៃការសិក្សាដែលកាន់តែល្អប្រសើរឡើង។

ជំនួយ *គូសាណូណេ* របស់ រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៤៧.៦លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និង អង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួ ន៤៧៤ គម្រោងនៅទូទាំងប្រទេស។




ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០

អ៊ីមែល: eco.jpn@.pp.mofa.go.jp

គេហទំព័រ: http://www.kh.emb-japan.go.jp